មាហាអយ្យការ
អមសាលាឧទ្ធរណ៍ ភ្នំពេញ
លេខ ១៦៦-៩៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

**ជម្រាបមក**

**លោកព្រះរាជអាជ្ញាតុលាការ ខេត្តព្រៃវែង**

**សូមជ្រាប។**

**កម្មវត្ថុ:** សេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត និងសិទ្ធិប្តឹងឧទ្ធរណ៍របស់អយ្យការ ។

**យោង:** លិខិតរបស់លោកលេខ ១១៤.៩៤ អក ចុះថ្ងៃទី០៣-០៩-៩៤ ។

តបតាមលិខិតខាងលើខ្ញុំសូមជម្រាបថា កាលណាលោកធ្វើ ដីកាសន្និដ្ឋានសុំឲ្យចៅក្រមស៊ើអង្កេត បានសេចក្តីថាលោកសុំទៅចៅក្រមឲ្យធ្វើការស៊ើបអង្កេតនៅក្នុងបទល្មើសព្រហ្មទណ្ឌណាមួយ ដើម្បីប្រមូលភស្តុតាងផ្សេងៗជាបន្ទុកចោទលើជនល្មើសដែលមានឈ្មោះរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះផង និងសុំឲ្យស្វែងរកជនល្មើសផ្សេងទៀតជាសហចារី ឬសុំឲ្យស្វែងរកជនសមគំនិត(បើមាន) ដែលចូលរួមប្រព្រឹត្តបទល្មើសជាមួយគ្នាផង ដើម្បីសម្រាប់លោកជាតំណាងអយ្យការប្រើប្រាស់ក្នុងឱកាសសវនាការ ធ្វើការចោទប្រកាន់ និងសុំឲ្យតុលាការកាត់ទោសជនល្មើស ។ភារកិច្ចរបស់លោកនេះត្រូវធ្វើយ៉ាងណាឲ្យបានដល់ការផ្តន្ទាទោសជនប្រព្រឹត្តអំពើល្មើស ។

ដូច្នេះទោះជាលោកធ្វើដីកាសន្និដ្ឋានសុំឲ្យចៅក្រមស៊ើបអង្កេត ហើយបញ្ជូនសំណុំរឿងនិងមនុស្សត្រូវចោទទៅចៅក្រមផុតពីលោកហើយក្តី ពុំមែនបានសេចក្តីថាភារកិច្ចរបស់លោកត្រូវចប់សព្វគ្រប់ត្រឹមប៉ុណ្ណោះទេ ។ លោកត្រូវតាមឃ្លាំមើលនៅជុំវិញបញ្ហាបទល្មើសដែលកើតមានហើនោះ តើចៅក្រមស៊ើបសួរប្រមូលបានភស្តុតាងផ្សេងៗចប់សព្វគ្រប់ហើយឬនៅ? ត្រូវធ្វើយ៉ាងណាទៀត? ដើម្បីស្រាវជ្រាវ? តើនៅក្នុងបទល្មើសនោះជនណាខ្លះបានប្រព្រឹត្ត? បានត្រូវរកឃើញខ្លួន ហើយសួរចោទប្រកាន់ហើយឬនៅ ?

នៅក្នុងបទល្មើសអាជ្ញាជាមជ្ឈិម ជាឧក្រិដ្ឋ ដែលច្បាប់ចែងទោពន្ធនាគារទាំងឡាយ លោកអាចសុំឲ្យឃុំខ្លួនតាមច្បាប់បញ្ញត្តិមកនោះ ព្រោះជនល្មើសអាចបង្កើតអំពើគ្រោះថ្នាក់ដល់សង្គមមនុស្សដ៏ទៃទៀត ទាំងផ្នែកសេចក្តីសុខសាន្ត ទាំងផ្នែកទ្រព្យសម្បត្តិ ។ល៕

ដូច្នេះបើចៅក្រមសម្រេចអនុញ្ញាតឲ្យជនល្មើសនៅក្រៅឃុំក្តី ឬសម្រេចលើកលែងចោទប្រកាន់ក្តី ហើយដីកាសម្រេចគ្មានទិដ្ឋាការ (បានឃើញនិងមានចុះលេខ ថ្ងៃ ខែ ឆ្នាំ និងហត្ថលេខា ជាផ្លូវការ) របស់លោកទេ លោកមានសិទ្ធិប្តឹងឧទ្ធរណ៍និងសេចក្តីសម្រេចនោះ ដោយលោកចុះនិទ្ទេសថាលោកបានទទួលដំណឹង ពីសេចក្តីសម្រេចនោះនៅថ្ងៃចុះបណ្តឹងឧទ្ធរណ៍ ដើម្បីសាលាឧទ្ធរណ៍ត្រួតពិនិត្យតាមច្បាប់តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៤

**អគ្គព្រះរាជអាជ្ញា**

**ហង់ រ៉ូ រ៉ាកេន**

ចម្លងជូន
-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
-គ្រប់ចៅក្រមស៊ើបអង្កេត
-គ្រប់លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង
-ដើម្បីជ្រាបជាព័ត៌មាន